


ការសាកល្បងដ៏ពិបាកបំផុត



ផ្នែក 3/3

Standing the Test
ដោយ ដេរេក ព្រីនស៍

ស៊េរីមេរៀនកេរដំណែលនៃសេចក្តីបង្រៀនរបស់យើងបច្ចុប្បន្ន បានផ្តោតលើការសាកល្បងក្នុងជីវិតគ្រីស្ទបរិស័ទ។ យើងបានឃើញថា ការសាកល្បងបង្កើតភាពអត់ធ្មត់ និងភាពចាស់ទុំខាងវិញ្ញាណ ដែលយើងត្រូវការដើម្បីឈានទៅដល់គោលដៅដ៏អស់កល្បជានិច្ចរបស់យើង គឺការគ្រងរាជ្យជាមួយព្រះគ្រីស្ទ។ យើងក៏បានពិភាក្សាអំពីគោលបំណងសំខាន់នៃការសាកល្បង និងរបៀបដែលយើងគួរឆ្លើយតបចំពោះការសាកល្បងទាំងនោះ។ នៅក្នុងលិខិតចុងក្រោយស្តីពីប្រធានបទនេះ យើងនឹងពិចារណាអំពី “ការសាកល្បងដ៏ពិបាកបំផុត”។

ការសាកល្បងដែលមិនបានរំពឹងទុក

ខ្ញុំសូមចាប់ផ្តើមដោយសួរថា៖ តើអ្នកគិតថា អ្វីជាការសាកល្បងដ៏ពិបាកបំផុតដែលគ្រីស្ទបរិស័ទត្រូវប្រឈម? ចម្លើយរបស់ខ្ញុំប្រហែលជាធ្វើឲ្យអ្នកភ្ញាក់ផ្អើល ប៉ុន្តែវាផ្អែកលើបទពិសោធន៍ជាង ៥០ ឆ្នាំ ក្នុងការបម្រើព្រះពេញម៉ោង។ ខ្ញុំជឿថា ការសាកល្បងដ៏ពិបាកបំផុតដែលអ្នក និងខ្ញុំអាចជួបប្រទះ ហើយជាការសាកល្បងដែលយើងពិបាកនឹងយកឈ្នះជាងគេ គឺ “ភាពជោគជ័យ”។

ស្តេចសាឡូម៉ូនបានព្រមានយើងថា

> “ការបង្ហើយអ្វីៗ នោះវិសេសជាងចាប់ផ្តើមការទៅទៀត ហើយដែលមានចិត្តអត់ធ្មត់ នោះវិសេសជាងមានចិត្តអំនួតដែរ” (សាស្តា 7:8)។

និយាយម្យ៉ាងទៀត៖ អ្វីដែលធ្វើឲ្យអ្នកក្លាយជាអ្នកឈ្នះ មិនមែនជារបៀបដែលអ្នកចាប់ផ្តើមការរត់ប្រណាំងនោះទេ ប៉ុន្តែជារបៀបដែលអ្នកបញ្ចប់វា។

មានគ្រូគង្វាលជនជាតិចិនម្នាក់បានបម្រើព្រះយ៉ាងស្មោះត្រង់ ហើយបានជាប់ពន្ធនាគារជាង ២០ ឆ្នាំ ដោយសារជំនឿរបស់គាត់ មុនពេលបានទៅនៅជាមួយព្រះអម្ចាស់។ គាត់បាននិយាយថា៖ “ខ្ញុំបានឃើញមនុស្សជាច្រើនចាប់ផ្តើមបានល្អ ប៉ុន្តែមានតិចណាស់ដែលបញ្ចប់បានល្អ”។ ខ្ញុំក៏អាចនិយាយដូចគ្នានេះផងដែរ។

នៅក្នុងផ្នែកបន្ទាប់ យើងនឹងពិចារណាអំពីស្តេចអ៊ីស្រាអែលមួយចំនួន ដែលជាគំរូនៃមនុស្សដែលទទួលបានភាពជោគជ័យ។

អំនួតរបស់ស្តេចសូល

សូល ជាស្តេចទីមួយនៃសាសន៍អ៊ីស្រាអែល។ នៅក្មេង គាត់ជាបុរសរឹងមាំ និងលេចធ្លោម្នាក់។ នៅដើមនៃការគ្រងរាជ្យ គាត់ទទួលបានជ័យជម្នះជាច្រើនក្នុងសង្គ្រាម។ ប៉ុន្តែ នៅពេលព្រះជាម្ចាស់ចាត់គាត់ឲ្យទៅប្រយុទ្ធនឹងពួកអាម៉ាឡេក គាត់បានអនុញ្ញាតឲ្យការខ្លាចមនុស្ស រារាំងគាត់មិនឲ្យស្តាប់បង្គាប់ព្រះទាំងស្រុង។ ជាលទ្ធផល ហោរាសាំយូអែលបានប្រាប់គាត់ថា ព្រះជាម្ចាស់បានបដិសេធគាត់មិនឲ្យធ្វើជាស្តេចទៀតទេ។

ឫសគល់នៃបញ្ហារបស់ស្តេចសូល ត្រូវបានសង្ខេបនៅក្នុងសាររបស់ហោរាសាំយូអែលថា៖

> “ក្នុងកាលដែលទ្រង់នៅថោកទាបដល់ព្រះនេត្រនៃអង្គទ្រង់ នោះតើព្រះមិនបានតាំងទ្រង់ឡើង ឲ្យធ្វើជាមេលើពូជអំបូរអ៊ីស្រាអែលទាំងប៉ុន្មានទេឬអី” (១ សាំយូអែល 15:17)។

ដរាបណាសូលនៅតែមានចិត្តរាបទាប ព្រះជាម្ចាស់អាចប្រទានពរដល់គាត់។ ប៉ុន្តែ នៅពេលគាត់ក្លាយជាមនុស្សអំនួត ព្រះជាម្ចាស់ត្រូវដកគាត់ចេញពីតំណែង។

គោលការណ៍នេះក៏អនុវត្តចំពោះអ្នក និងខ្ញុំផងដែរ។ នៅពេលយើងចាត់ទុកខ្លួនឯងថាតូច នោះយើងទុកកន្លែងឲ្យភាពធំអស្ចារ្យរបស់ព្រះបើកសម្តែងតាមរយៈជីវិតយើង។ ប៉ុន្តែ នៅពេលយើងចាត់ទុកខ្លួនឯងថាធំ នោះយើងលែងទុកកន្លែងឲ្យព្រះបង្ហាញភាពធំអស្ចារ្យរបស់ទ្រង់តាមរយៈយើងទៀតហើយ។ នៅទីបញ្ចប់ អំនួតរបស់ស្តេចសូលបាននាំគាត់ទៅរកវិនាសកម្ម។ នៅយប់ចុងក្រោយនៃជីវិតរបស់គាត់ គាត់បានទៅពិគ្រោះជាមួយអ្នកគ្រូធ្មប់ ហើយនៅថ្ងៃបន្ទាប់ គាត់បានសម្លាប់ខ្លួនឯងនៅក្នុងសមរភូមិ។

ការភ្លេចខ្លួនរបស់ស្តេចដាវីឌ

ដាវីឌ ជាស្តេចបន្ទាប់នៃសាសន៍អ៊ីស្រាអែល និងជាអ្នកសំណព្វរបស់ព្រះជាម្ចាស់។ អស់រយៈពេលជាច្រើនឆ្នាំ គាត់រស់នៅជាជនភៀសខ្លួន ត្រូវស្តេចសូលតាមបៀតបៀន និងតាមប្រមាញ់ឥតឈប់ឈរ។ ទោះជាយ៉ាងណា គាត់បានឆ្លងកាត់ការលំបាកទាំងអស់ដោយជ័យជម្នះ ហើយនៅទីបំផុតគាត់អាចថ្លែងទីបន្ទាល់ដ៏អស្ចារ្យថា៖

> ព្រះយេហូវ៉ាទ្រង់បានប្រទានរង្វាន់មក តាមសេចក្តីសុចរិតរបស់ទូលបង្គំ ទ្រង់បានសងទូលបង្គំ តាមសេចក្តីបរិសុទ្ធនៃដៃទូលបង្គំ ដ្បិតទូលបង្គំបានកាន់តាមអស់ទាំងផ្លូវរបស់ព្រះយេហូវ៉ា ហើយមិនបានថយចេញពីព្រះនៃទូលបង្គំ ដោយប្រព្រឹត្តសេចក្តីអាក្រក់ឡើយ។ (ទំនុកតម្កើង 18:20-21)

ប៉ុន្តែ ក្រោយមក ដាវីឌបានផ្លាស់ប្តូរ ហើយពាក្យសម្តីរបស់គាត់ក៏ផ្លាស់ប្តូរដែរ៖

> ឱព្រះអង្គអើយ សូមអាណិតមេត្តាដល់ទូលបង្គំ តាមសេចក្តីសប្បុរសរបស់ទ្រង់ ហើយសូមលុបសេចក្តីរំលងរបស់ទូលបង្គំចេញ ដោយសេចក្តីមេត្តាករុណាដ៏បរិបូររបស់ទ្រង់ សូមលាងទូលបង្គំឲ្យយ៉ាងស្អាតពីអំពើទុច្ចរិតរបស់ទូលបង្គំ សូមសម្អាតអំពើបាបរបស់ទូលបង្គំផង។ (ទំនុកតម្កើង 51:1-2)

តើមានអ្វីកើតឡើង? ហេតុអ្វីបានជាមានការផ្លាស់ប្តូរបែបនេះ? ស្តេចដាវីឌបានទទួលបទពិសោធន៍នៃភាពជោគជ័យគ្រប់យ៉ាង។ គាត់ត្រូវបានតាំងជាស្តេចលើអ៊ីស្រាអែលទាំងមូល ឈ្នះសត្រូវទាំងអស់ និងកំពុងរីករាយនឹងភាពជោគជ័យ។ គាត់លែងចេញទៅធ្វើសង្គ្រាមទៀតហើយ។ ផ្ទុយទៅវិញ គាត់ស្នាក់នៅក្នុងរាជវាំងនៅក្រុងយេរូសាឡិម ដោយមានសេរីភាពធ្វើអ្វីៗតាមចិត្តប្រាថ្នា។

នៅក្នុងស្ថានភាពនេះ គាត់មិនស្ទាក់ស្ទើរក្នុងការល្បួងនាងបាតសេបា ដែលជាប្រពន្ធរបស់លោកអ៊ូរី ជាអ្នកជិតខាងរបស់គាត់ឡើយ។ គាត់ក៏បានរៀបចំផែនការសម្លាប់លោកអ៊ូរី ដើម្បីបិទបាំងអំពើបាបរបស់ខ្លួនផងដែរ។ នៅក្នុងពេលដែលដាវីឌទទួលបានភាពជោគជ័យ គាត់បានភ្លេចគោលការណ៍ដែលគាត់ធ្លាប់ប្រកាន់ខ្ជាប់មុនពេលក្លាយជាស្តេច។

យើងអរព្រះគុណព្រះអម្ចាស់ដែលនៅទីបំផុត ដាវីឌបានប្រែចិត្ត ហើយព្រះជាម្ចាស់ក៏បានអត់ទោសឲ្យគាត់។ ទោះជាយ៉ាងណា អំពើបាបរបស់ដាវីឌបានបន្សល់ទុកនូវស្រមោលដ៏ងងឹតលើកូនចៅរបស់គាត់ពីមួយជំនាន់ទៅមួយជំនាន់។ ព្រះជាម្ចាស់បានមានបន្ទូលព្រមានគាត់ថា៖ "ដូច្នេះ ដាវមិនដែលឃ្លាតពីគ្រួឯងឡើយ..." (សាំយូអែល 12:10)។ យើងត្រូវចងចាំថា ទោះបីព្រះជាម្ចាស់អត់ទោសអំពើបាបរបស់យើងក៏ដោយ ក៏វាមិនមានន័យថា ផលវិបាកទាំងអស់នៃអំពើបាបរបស់យើងនឹងត្រូវលុបចោលឡើយ។

ការថ្វាយបង្គំរូបព្រះរបស់ស្តេចសាឡូម៉ូន

សាឡូម៉ូន ជាបុត្ររបស់ស្តេចដាវីឌ ហើយបានស្នងរាជ្យបន្តពីបិតារបស់គាត់។ គាត់ជាមនុស្សដែលព្រះជាម្ចាស់ស្រឡាញ់ និងជ្រើសរើស ដោយសារគាត់បានបន្ទាបខ្លួន ទទួលស្គាល់ថាខ្លួនត្រូវការប្រាជ្ញា ព្រះជាម្ចាស់ក៏ប្រទានទាំងប្រាជ្ញា ទ្រព្យសម្បត្តិ និងកិត្តិយសដល់គាត់ផងដែរ។ សាឡូម៉ូនបានក្លាយជាស្តេចដែលមានប្រាជ្ញាបំផុត មានទ្រព្យសម្បត្តិច្រើនបំផុត និងល្បីល្បាញបំផុតក្នុងចំណោមស្តេចទាំងអស់នៃអ៊ីស្រាអែល។

ប៉ុន្តែ ទោះបីជាគាត់មានប្រាជ្ញាយ៉ាងណាក៏ដោយ សាឡូម៉ូនមិនបានឆ្លងផុតការសាកល្បងនៃភាពជោគជ័យបានឡើយ។

> ដ្បិតកាលណាសាឡូម៉ូនទ្រង់ចាស់ហើយ នោះភរិយាទ្រង់បានបង្វែរព្រះទ័យទ្រង់ឲ្យទៅតាមព្រះដទៃវិញ... ពីព្រោះសាឡូម៉ូនទ្រង់ប្រតិបត្តិតាមព្រះអាសថារ៉ូត ជាព្រះនៃពួកស៊ីដូន ហើយតាមព្រះមីលកូម ជាសេចក្តីគួរខ្ពើមរបស់ពួកអាំម៉ូនដែរ សាឡូម៉ូនក៏ប្រព្រឹត្តការដែលអាក្រក់នៅព្រះនេត្រនៃព្រះយេហូវ៉ា... ។ (១ ពង្សាវតារក្សត្រ 11:4-6)

ទោះបីសាឡូម៉ូនមានការចាប់ផ្តើមដ៏អស្ចារ្យក៏ដោយ ចុងបញ្ចប់នៃជីវិតរបស់គាត់ គាត់បានស្លាប់ក្នុងស្ថានភាពជាអ្នកថ្វាយបង្គំព្រះក្លែងក្លាយ។

ស្តេចពីរអង្គផ្សេងទៀត

បន្ទាប់ពីរជ្ជកាលរបស់សាឡូម៉ូន នគរអ៊ីស្រាអែលបានបែកចេញជាពីរ។ ស្តេចទាំងអស់នៃនគរខាងជើង (អ៊ីស្រាអែល) បានបែរទៅថ្វាយបង្គំព្រះក្លែងក្លាយ ហើយត្រូវព្រះអម្ចាស់បដិសេធ។ ចំណែកឯស្តេចជាច្រើននៃនគរខាងត្បូង (យូដា) ក៏បានបោះបង់ព្រះជាម្ចាស់ ហើយធ្លាក់ចូលក្នុងការថ្វាយបង្គំព្រះក្លែងក្លាយដែរ។ ទោះជាយ៉ាងណា មានស្តេចសុចរិតមួយចំនួននៅក្នុងនគរយូដា។ ប៉ុន្តែ គ្មានស្តេចណាម្នាក់អាចឆ្លងកាត់ការសាកល្បងនៃភាពជោគជ័យបានយ៉ាងពេញលេញឡើយ។

ស្តេចហេសេគាបានធ្វើកំណែទម្រង់យ៉ាងធំ ហើយបានស្តារការថ្វាយបង្គំព្រះយេហូវ៉ាឡើងវិញ។ នៅពេលស្តេចសានហេរីប ជាស្តេចអាសស៊ើរ បានឡោមព័ទ្ធក្រុងយេរូសាឡិម ព្រះអម្ចាស់បានធ្វើអន្តរាគមន៍ និងប្រទានការរំដោះដ៏អស្ចារ្យដល់ហេសេគា និងប្រជាជនរបស់គាត់។

ក្រោយមក នៅពេលហេសេគាឈឺជិតស្លាប់ ព្រះជាម្ចាស់មិនត្រឹមតែប្រោសគាត់ឲ្យជាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងប្រទានទីសម្គាល់ដ៏អស្ចារ្យ ដោយធ្វើឲ្យស្រមោលព្រះអាទិត្យថយក្រោយ ហើយទ្រង់បានសន្យាបន្ថែមអាយុឲ្យគាត់ ១៥ ឆ្នាំទៀត។

ទីសម្គាល់ដ៏អស្ចារ្យនៃស្រមោលព្រះអាទិត្យនេះ បានធ្វើឲ្យកិត្តិនាមរបស់ហេសេគាល្បីដល់បណ្តាប្រទេសផ្សេងៗ។ ជាហេតុ នាំឲ្យរាជទូតពីបាប៊ីឡូនមកសួរសុខទុក្ខគាត់។ ដោយសារមានអារម្មណ៍រីករាយនឹងការយកចិត្តទុកដាក់របស់ពួកគេ ហេសេគាបានបង្ហាញទ្រព្យសម្បត្តិ និងអ្វីៗដ៏មានតម្លៃទាំងអស់នៅក្នុងនគររបស់គាត់។ ប៉ុន្តែ គាត់មិនបានថ្វាយសិរីល្អដល់ព្រះជាម្ចាស់ទេ!

ព្រះគម្ពីរបានកត់ត្រាថា៖

> ប៉ុន្តែ ហេសេគាទ្រង់មិនបានសងព្រះគុណតាមដែលព្រះបានប្រោសដល់ទ្រង់នោះទេ ដ្បិតទ្រង់មានព្រះទ័យយកកម្តើងធំឡើង [ចាប់ផ្តើមមានអំនួត]។ (២ របាក្សត្រ 32:25)។

ក្រោយមក ក្នុងប្រវត្តិសាស្ត្រនៃនគរយូដា មានស្តេចសុចរិតម្នាក់ទៀត គឺយ៉ូសៀស។ ដូចហេសេគាដែរ គាត់បានធ្វើកំណែទម្រង់យ៉ាងធំ ស្តារការថ្វាយបង្គំព្រះយេហូវ៉ាឡើងវិញ និងបំផ្លាញអាសនៈថ្វាយបង្គំព្រះក្លែងក្លាយនៅបេតអែល ក្នុងនគរខាងជើង។

ប៉ុន្តែ ភាពជោគជ័យរបស់យ៉ូសៀសបានធ្វើឲ្យគាត់មានទំនុកចិត្តលើខ្លួនឯងខ្លាំងពេក ហើយគាត់បានប្រព្រឹត្តដោយប្រញាប់ប្រញាល់។ ដោយមិនបានស្វែងរកព្រះហឫទ័យរបស់ព្រះអម្ចាស់ និងទោះបីមានការព្រមានយ៉ាងច្បាស់ក៏ដោយ គាត់បានចេញទៅប្រយុទ្ធនឹងស្តេចផារ៉ោននេកូ នៃស្រុកអេស៊ីព្ទ ហើយត្រូវស្លាប់នៅក្នុងសមរភូមិ។ ជាមួយនឹងការស្លាប់របស់យ៉ូសៀស ក្តីសង្ឃឹមចុងក្រោយរបស់នគរយូដាក៏រលត់ទៅដែរ។

មនុស្សជោគជ័យនៅក្នុងព្រះគម្ពីរសញ្ញាថ្មី

ចុះនៅក្នុងព្រះគម្ពីរសញ្ញាថ្មីវិញ? តើវាផ្តល់ស្តង់ដារផ្សេងសម្រាប់ការដោះស្រាយភាពជោគជ័យឲ្យបានត្រឹមត្រូវដែរឬទេ? សូមយើងពិនិត្យមើលបុគ្គលសំខាន់ៗបំផុត៖ ព្រះយេស៊ូវផ្ទាល់ និងសិស្សរបស់ទ្រង់បីនាក់ គឺពេត្រុស យ៉ូហាន និងប៉ុល។ តើជីវិតរបស់ពួកគេបានបញ្ចប់យ៉ាងដូចម្តេច?

ព្រះយេស៊ូវ ពិតជាពិសេសលើសគេ ទ្រង់ជាព្រះបុត្រារបស់ព្រះដែលល្អឥតខ្ចោះ និងគ្មានបាបសោះ។ ទ្រង់មិនដែលបរាជ័យឡើយ។ ប៉ុន្តែ ទីបញ្ចប់នៃជីវិតនៅលើផែនដីរបស់ទ្រង់ គឺត្រូវគេឆ្កាងនៅលើឈើឆ្កាង ដោយអាក្រាតកាយ និងត្រូវមនុស្សបាបចំអកមើលងាយ។ នោះគឺជារូបភាពចុងក្រោយដែលពិភពលោកបានឃើញព្រះយេស៊ូវ។ ក្រោយមក ការរស់ឡើងវិញ និងសិរីរុងរឿងរបស់ទ្រង់ ត្រូវបានបង្ហាញតែដល់ “ពួកស្មរបន្ទាល់ដែលព្រះបានរើសអំពីមុនមក” (កិច្ចការ 10:41) ប៉ុណ្ណោះ។ ចំពោះលោកីយ៍វិញ ព្រះជាម្ចាស់មិនបង្ហាញឲ្យពួកគេឃើញឡើយ។

ចុះពេត្រុស ដែលជាអ្នកដឹកនាំសាវកទាំងដប់ពីរវិញ? យោងតាមប្រពៃណីដែលអាចទុកចិត្តបាន ពេត្រុសក៏បានបញ្ចប់ជីវិតនៅលើឈើឆ្កាងដែរ។ តាមសំណូមពររបស់គាត់ផ្ទាល់ គាត់ត្រូវបានឆ្កាងដោយក្បាលចុះក្រោម ពីព្រោះគាត់គិតថា ខ្លួនមិនសមនឹងរងទុក្ខដូចព្រះអម្ចាស់របស់គាត់ឡើយ។

យើងមិនមានកំណត់ត្រាច្បាស់លាស់អំពីការស្លាប់របស់យ៉ូហានទេ។ ប៉ុន្តែយើងដឹងថា នៅវ័យចាស់ គាត់ត្រូវបាននិរទេសទៅកាន់កោះប៉ាត្មុស ដែលជាកោះស្ងួតហួតហែង និងមានថ្មច្រើន។ នៅទីនោះ គាត់បានទទួលការបើកសម្តែងដែលត្រូវបានកត់ត្រាទុកនៅក្នុងព្រះគម្ពីរវិវរណៈ។

ចុះប៉ុលវិញ? គាត់បានរៀបរាប់ពីជីវិតរបស់ខ្លួន និងសាវកដទៃទៀតថា៖

> “លុះមកដល់ឥឡូវនេះ យើងខ្ញុំត្រូវទាំងឃ្លាន ទាំងស្រេក ហើយនៅអាក្រាត ទាំងត្រូវគេវាយ ហើយក៏ដើរសាត់អណ្តែត យើងខ្ញុំធ្វើការនឿយហត់នឹងដៃយើង កាលណាគេជេរ នោះយើងខ្ញុំឲ្យពរវិញ កាលណាគេបៀតបៀន នោះយើងខ្ញុំទ្រាំទ្រ កាលណាគេប្រមាថ នោះយើងខ្ញុំអង្វរដល់គេ យើងខ្ញុំបានត្រឡប់ដូចជាសំរាមរបស់លោកីយ៍ ហើយដូចជាកំអែលនៃមនុស្សទាំងអស់ ដរាបដល់ឥឡូវនេះ” (១ កូរិនថូស 4:11-13)។

នៅចុងបញ្ចប់នៃព័ន្ធកិច្ចដ៏មានអំណាច និងពោរពេញដោយអព្ភូតហេតុ ដែលបានបើកផ្លូវឲ្យសាសន៍ដទៃទទួលដំណឹងល្អ ប៉ុលបានឃើញខ្លួនឯងជាប់ច្រវាក់នៅក្នុងគុកដ៏ត្រជាក់មួយក្នុងទីក្រុងរ៉ូម ហើយត្រូវបានបោះបង់ចោលដោយសហការីជិតស្និទ្ធខ្លះៗរបស់គាត់។ ពីទីនោះ គាត់ត្រូវបាននាំចេញទៅប្រហារជីវិតជាសាធារណៈដោយកាត់ក្បាល។

តើរឿងទាំងនេះបង្រៀនយើងពីអ្វី?

តើកំណត់ត្រាអំពីព្រះយេស៊ូវ ពេត្រុស យ៉ូហាន និងប៉ុលទាំងនេះ មានន័យថាគ្រីស្ទបរិស័ទទាំងអស់ដែលមានការប្តេជ្ញាចិត្តយ៉ាងមុតមាំចំពោះព្រះ ត្រូវតែស្លាប់ក្នុងនាមជាអ្នករងទុក្ខវេទនាដោយសារជំនឿមែនឬ? ឬមានន័យថា គ្រីស្ទបរិស័ទដែលមានការប្តេជ្ញាចិត្តចំពោះព្រះ មិនអាចក្លាយជាអ្នកមានទ្រព្យសម្បត្តិសុកស្តុកបានឡើយមែនឬ? ទេ! ប៉ុន្តែកំណត់ត្រាទាំងនេះបានបញ្ជាក់យ៉ាងច្បាស់នូវចំណុចដ៏សំខាន់បំផុតមួយថា យើងមិនត្រូវអនុញ្ញាតឱ្យលោកិយល្បួងយើងឱ្យទទួលយកខ្នាតវាស់វែងនៃភាពជោគជ័យរបស់វាឡើយ។ យើងក៏មិនត្រូវស្វែងរកការទទួលស្គាល់ពីលោកិយនោះដែរ។

បំណងប្រាថ្នាចង់បានប្រជាប្រិយភាព តែងតែជារឿងគ្រោះថ្នាក់។ ព្រះយេស៊ូវបានមានបន្ទូលព្រមានយ៉ាងខ្លាំងអំពីបំណងនេះ។ ទ្រង់មានបន្ទូលទៅកាន់ពួកផារិស៊ីថា៖

> “ដ្បិតរបស់ណាដែលមនុស្សគាប់ចិត្តរាប់អានជាច្រើន នោះជាទីស្អប់ខ្ពើមនៅចំពោះព្រះវិញ” (លូកា 16:15)។

ហើយទ្រង់ក៏មានបន្ទូលទៅកាន់សិស្សរបស់ទ្រង់ថា៖

> “វេទនាដល់អ្នករាល់គ្នា កាលណាមនុស្សទាំងអស់និយាយល្អពីអ្នករាល់គ្នា ពីព្រោះកាលពីដើម ពួកឰយុកោបានប្រព្រឹត្តនឹងពួកហោរាក្លែងក្លាយយ៉ាងដូច្នោះដែរ” (លូកា 6:26)។

គន្លឹះនៃភាពជោគជ័យពិតប្រាកដ

នៅពេលខ្ញុំបានពិចារណាអំពីគំរូទាំងនេះ ខ្ញុំបានប្រៀបធៀបចុងបញ្ចប់នៃជីវិតរបស់ស្តេចទាំងប្រាំអង្គក្នុងគម្ពីរសញ្ញាចាស់ ជាមួយនឹងចុងបញ្ចប់នៃជីវិតរបស់ព្រះយេស៊ូវ និងអ្នកដើរតាមព្រះអង្គ។ ខ្ញុំបានសួរខ្លួនឯងថា៖ «តើអ្វីទៅជាគន្លឹះដ៏សំខាន់ក្នុងការសម្រេចបាននូវភាពជោគជ័យដែលស្ថិតស្ថេរយូរអង្វែង?»

ព្រះអម្ចាស់បានដឹកនាំខ្ញុំទៅកាន់បទគម្ពីរពីរកន្លែង។ ទីមួយ គឺពាក្យដែលលោកប៉ុលបានលើកនៅក្នុង ១ កូរិនថូស 7:25

> “តែខ្ញុំសម្តែងដោយគំនិតខ្ញុំ ទុកដូចជាបានទទួលសេចក្តីមេត្តាករុណាមកពីព្រះអម្ចាស់ ឲ្យបានគួរជឿដែរ”។

ខ្ញុំបានយល់ថា ដើម្បីរក្សាភាពស្មោះត្រង់ និងទទួលបានភាពជោគជ័យពិតប្រាកដ ខ្ញុំត្រូវតែពឹងផ្អែកទាំងស្រុងលើសេចក្តីមេត្តាករុណារបស់ព្រះអម្ចាស់។ ខ្ញុំមិនអាចពឹងផ្អែកលើអ្វីផ្សេងទៀតបានទេ មិនថាជា៖ ការសិក្សារបស់ខ្ញុំ អំណោយទានខាងវិញ្ញាណរបស់ខ្ញុំ សមិទ្ធផលកន្លងមក ឬគ្រប់ទាំងឆ្នាំដែលខ្ញុំបានបម្រើក្នុងជីវិតជាគ្រីស្ទបរិស័ទនោះទេ។ មានតែរឿងមួយប៉ុណ្ណោះ ដែលអាចរក្សាខ្ញុំឲ្យស្មោះត្រង់បាន គឺសេចក្តីមេត្តាករុណារបស់ព្រះជាម្ចាស់។

ខ្ញុំត្រូវធ្វើឲ្យវាក្លាយជាគោលបំណងសំខាន់បំផុតនៃជីវិតរបស់ខ្ញុំ ទាំងដឹងខ្លួន និងបន្តទៅមុខ ដោយការពឹងផ្អែកលើសេចក្តីមេត្តាករុណារបស់ព្រះអម្ចាស់។ ខ្ញុំក៏ត្រូវប្រុង

ប្រយ័ត្នចំពោះអ្វីៗដែលអាចធ្វើឲ្យខ្ញុំភ្លេចថា ខ្ញុំត្រូវការពឹងផ្អែកលើព្រះ។ ជាពិសេស ខ្ញុំត្រូវប្រយ័ត្នចំពោះអំនួត ពីព្រោះអំនួតគឺជាការពឹងផ្អែកលើខ្លួនឯង។

ទីពីរ គឺព្រះបន្ទូលរបស់ព្រះយេស៊ូវនៅក្នុង យ៉ូហាន 4:34៖

> “ឯអាហារខ្ញុំ គឺត្រង់ដែលខ្ញុំធ្វើតាមព្រះហឫទ័យនៃព្រះ ដែលចាត់ឲ្យខ្ញុំមក ព្រមទាំងបង្ហើយការរបស់ទ្រង់នោះឯង”។

អាហារដែលជាប្រភពនៃជីវិត និងកម្លាំងរបស់ព្រះយេស៊ូវ គឺការប្តេជ្ញាចិត្តធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដោយឥតងាករេ រហូតដល់ទីបញ្ចប់នៃជីវិតរបស់ទ្រង់។ នោះហើយជាភាពជោគជ័យពិតប្រាកដដែលអ្នក និងខ្ញុំគួរខិតខំស្វែងរក។ តើភាពជោគជ័យបែបនេះ ជាក្តីសង្ឃឹម និងគោលដៅរបស់អ្នកដែរឬទេ?

ឱព្រះវរបិតាអើយ! ទូលបង្គំចង់ទទួលបានភាពជោគជ័យក្នុងជីវិត ប៉ុន្តែជាភាពជោគជ័យដែលគាប់ព្រះហឫទ័យទ្រង់ និងសម្រេចតាមផែនការដែលទ្រង់មានសម្រាប់ទូលបង្គំ។ ដោយសារសេចក្តីមេត្តាករុណាដ៏ធំធេងរបស់ទ្រង់ សូមជួយទូលបង្គំឲ្យជៀសផុតពីអំនួត ហើយឲ្យការធ្វើតាមព្រះហឫទ័យរបស់ទ្រង់ ក្លាយជាគោលបំណងដ៏សំខាន់បំផុតនៃជីវិតទូលបង្គំ រហូតដល់ថ្ងៃចុងក្រោយ។ សូមអរព្រះគុណព្រះអម្ចាស់។អាម៉ែន!

ការបង្រៀនតាមរយៈសំបុត្រ
ប្រតិចារិក: TL-L135-100-KHM
បច្ចុប្បន្នភាពចុងក្រោយ: 10 Nov 2026
គេហទំព័រ: Derekprince.com/km/resources

